គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision: A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

រាជធានីភ្នំពេញ,ថ្ងៃទី១១រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ត្រូវនឹងថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# គោលជំហរ និងសកម្មភាពខុមហ្វ្រែល

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា (ខុមហ្វ្រែល) សូមជម្រាបជូនដល់សាធារណជនថា ខុមហ្វ្រែលមិនមានជំហរ និងមិនមានសកម្មភាពដើម្បីបំផ្លាញការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ដូចមតិចោទប្រកាន់នៃប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកមួយចំនួននាពេលថ្មីៗនេះទេ។ ផ្ទុយទៅវិញ ខុមហ្វ្រែលបំពេញបេសកកម្ម និងកំពុងខិតខំអនុវត្តសកម្មភាពរបស់ខ្លួន ដើម្បីបុព្វហេតុនៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌តាមបែបប្រជាធិបតេយ្យត្រឹមត្រូវនៅកម្ពុជា។

ខុមហ្វ្រែលមានសកម្មភាពជាច្រើនរួមទាំងការសង្កេតការណ៍បោះឆ្នោត ការអប់រំ និងការផ្សព្វផ្សាយការបោះឆ្នោត ការតស៊ូមតិ និងការផ្តល់មតិយោបល់កែលម្អនៅគ្រប់ដំណាក់កាលតាំងការបង្កើតក្របខណ្ឌច្បាប់ ការរៀបចំការបោះឆ្នោត ប្រព័ន្ធចុះឈ្មោះ និងបញ្ជីឈ្មោះបោះឆ្នោត ការចុះឈ្មោះគណបក្សនយោបាយ ការឃោសនា រហូតដល់ការប្រកាសលទ្ធផលបោះឆ្នោត និងមន្ត្រីជាប់ឆ្នោត។ រាល់សកម្មភាពរបស់ខុមហ្វ្រែលទាំងអស់ត្រូវភ្ជាប់លទ្ធផលរំពឹងទុក និងការពិនិត្យលើហានិភ័យ និងលើគោលការណ៍ជាតិ និងអន្តរជាតិ ថាតើខុមហ្វ្រែលគួរចូលរួម និងមានសកម្មភាព ដោយវិធីសាស្ត្របៀបណាមួយ។

លោក គល់ បញ្ញា នាយកប្រតិបត្តិខុមហ្វ្រែលលើកឡើងថា លោកមានជំនឿយ៉ាងមុតមាំចំពោះការខិតខំក្នុងសកម្មភាពតស៊ូមតិ ដើម្បីស្ថានភាពនៃការបោះឆ្នោត ឆ្នាំ២០១៨ ដោយសេរី យុត្តិធម៌ និងមានការប្រកួតប្រជែងតាមបែបប្រជាធិបតេយ្យសេរីពហុបក្សត្រឹមត្រូវ និងការគោរពឆន្ទៈរបស់ម្ចាស់ឆ្នោតឡើងវិញ។ ទាំងនេះគឺជាមូលដ្ឋានគ្រឹះសម្រាប់រក្សាស្ថេរភាព សន្តិភាព និងផ្តល់អាណត្តិស្របច្បាប់ដល់អំណាចរដ្ឋទាំងនីតិបញ្ញត្តិនិងនីតិប្រតិបត្តិ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង លោក កន សាវាង្ស តាមរយៈទូរស័ព្ទ ០១១ ៨៨៤ ៨៤០

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org